# សន្ទរកថាស្វាគមន៍ របស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិសាកលនៃមណ្ឌលប៉ាស៊ីហ្វិកខាងលិច ក្នុងឱកាសបើកកិច្ចប្រជុំមណ្ឌលលើកទី៣

**ថ្ងៃទី ៦-៧ ខែខុសតា ឆ្នាំ២០១៩**

**ទីក្រុងព័រម៉ូរេសប៊ី ប្រទេសប៉ាពូអាស៊ីណូវែលហ្គីណេ**

- ឯកឧត្តម Pascoe Kase រដ្ឋលេខាធិការក្រសួងសុខាភិបាលប៉ាពូអាស៊ីណូវែលហ្គីណេ
- លោកជំទាវ Roslyn Morauta សមាជិកក្រុមប្រឹក្សាភិបាលផ្លាស់វេនរបស់មូលនិធិសកល
- លោកស្រី Catherine Wilson ស្នងការជាន់ខ្ពស់រងអូស្រ្តាលីប្រចាំប៉ាពូអាស៊ីណូវែលហ្គីណេ
- វេជ្ជបណ្ឌិត Percy Pokea តំណាងលោកជំទាវឯកអគ្គរដ្ឋទូតអាម៉េរិកប្រចាំប៉ាពូអាស៊ីណូវែលហ្គីណេ
- លោក Davis Bridger នាយកអង្គការយូអិនអេដស៍ និងជាតំណាងអង្គការសហប្រជាជាតិប្រចាំប៉ាពូអាស៊ីណូវែលហ្គីណេ
- លោកស្រី Raegan Boler មន្ត្រីជាន់ខ្ពស់ការិយាល័យកិច្ចការក្រុមប្រក្សាភិបាលមូលនិធិសកល ទីប្រឹក្សាបច្ចេកទេសពីអង្គការយូអិនអេដស៍ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក
- ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវចូលរួមទាំងអស់

ជាបឋមនេះ ខ្ញុំសូមសម្តែងនូការកោតសសើរដោយស្មោះ ចំពោះឯកឧត្តម រដ្ឋលេខាធិការក្រសួងសុខាភិបាល ប៉ាពូអាស៊ីណូវែលហ្គីណេ ដែលបានចំណាយពេលអញ្ជើញចូលរួមបើកកិច្ចប្រជុំលើកទី៣នៃមណ្ឌលតំណាងប៉ាស៊ីហ្វិកខាងលិចរបស់យើងពេលនាពេលនេះ។ វត្តមានរបស់ឯកឧត្តម និងភ្ញៀវចូលរួមទាំងអស់ បានផ្តល់កិត្តិយសអោយកិច្ចប្រជុំរបស់យើងមានសារសំខាន់វិសេសវិសាល។ នេះបានបង្ហាញថា ប្រទេស ប៉ាពូអាស៊ីណូវែលហ្គីណេ បានបង្ហាញនូវ ការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងដ៏ពិសេស ក្នុងការប្រយុទ្ធប្រឆាំងជាមួយជំងឺទាំង៣ អេដស៍ របេង និងគ្រុនចាញ់ ដែលកំពុងគម្រាមកំហែងដល់ជីវភាពរស់នៅ និងសុខមាលភាពរបស់ពលរដ្ឋយើង នៅទូទាំងពិភពលោក។

ក្នុងនាមតំណាងនៃមណ្ឌលប៉ាស៊ីហ្វិកខាងលិច ខ្ញុំសូម ឈ្លាតយកឱកាសនេះសម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅ ជូនលោកជំទាវ Roslyn Morauta ដែលបានជាប់ឆ្នោតជាអនុប្រធានក្រុម

ប្រឹក្សាភិបាលមូលនិធិសាកលក្នុងអាណត្តបន្ទាប់ ការជាប់ឆ្នោតរបស់លោកជំទាវ បានធ្វើអោយពួកយើងមានមោទនភាពយ៉ាងខ្លាំង។ យើងទាំងអស់គ្នា សូមជូនពរជូនលោកជំទាវ ទទួលបានជោគជ័យក្នុងភារកិច្ចថ្មីរបស់លោកជំទាវ។ មណ្ឌលប៉ាស៊ីហ្វិកខាងលិចនឹងស្ថិតនៅជាមួយលោកជំទាវ យើងគាំទ្រ និងជួយលោកជំទាវ សម្រេចបានជោគជ័យបំពេញកិច្ចការថ្មីនេះ។ យើងសូមថ្លែងអំណរគុណជាពិសេសដែលបានទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ នៅប៉ាពូអាស៊ីណូវែលហ្គីណេ និង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្តៅរបស់ របស់លោកជំទាវ និងក្រុមការងារ។

សហការី សមាជិកមណ្ឌលតំបន់ និង សមាជិកក្រុមផ្តល់យោបល់ និងសហការីដែលបាន ចូលរួមទាំងអស់ ជំនួសមុខអោយថ្នាក់ដឹកនាំមណ្ឌលតំណាង ខ្ញុំមានសេចក្តីរីករាយពិតប្រាកដ ស្វាគមន៍ កិច្ចប្រជុំសមាជិកមណ្ឌលតំណាងប៉ាស៊ីហ្វិកខាងលិច ។ ក្នុងរយៈពេល២ថ្ងៃនេះ យើងនឹងចែករំលែកនូវព័តមានអំពីវឌ្ឍភាពនៃកិច្ចការរួមរបស់ យើងក្នុងមណ្ឌលតំណាង និងក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាភិបាលមូលនិធិសាកលផង។ យើងនឹងពិនិត្យឡើងវិញ និតិវិធីប្រតបត្តិនៃមណ្ឌលតំណាងរប់យើង និងអាចធ្វើការកែ សម្រួលខ្លះប្រសិនចាំបាច់ ដើម្បីធានាតម្លាភាព ភាពស័ក្តសិទ្ធ ប្រសិទ្ធភាព អោយបាន ស្របទៅតាមបទដ្ឋាន ក្បួនច្បាប់ និងបទពិសោធន៍ល្អៗ នៃមូលនិធិសាកល។

ខ្ញុំសង្ឃឹមថា លទ្ធផលនៃការពិគ្រោះពិភាក្សារបស់យើង និងជួយអោយយើងកំណត់គំហើញ ដូចគ្នាលើបញ្ហាដែលបានលើកឡើងជារបៀបវរនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលមូលនិធិសាកលលើកទី៤១។ ឯកសារជំហរទស្សនៈរួម នៃមណ្ឌលតំណាងប៉ាស៊ីហ្វិកខាងលិច សំរាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលខាងមុខ នឹងក្លាយជាសំឡេងរបស់មណ្ឌល តំណាង ដែលនឹងត្រូវបានស្តាប់ ហើយក៏ជួយសម្រួលអោយថ្នាក់ដឹកនាំមណ្ឌលតំណាង ងាយស្រួលបំពេញការងារនៅក្នុងកិច្ចប្រជុំផង។

ខ្ញុំផ្ទាល់ សូមលើកទឹកចិត្តឯកឧត្តម លោកជំទាវ លោក លោកស្រី ចូលរួមដោយសកម្ម ក្នុងកិច្ចពិភាក្សាលើរបៀបវរៈទាំងអស់របស់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ បញ្ហា ការគៀងគរមូលនិធិ នឹងកំណត់ការបែងចែកប្រើប្រាស់មូលនិធិ ក្នុងរយៈពេលគម្រោង បន្ទាប់។ ដូចនេះហើយបានជាការជជែកស៊ីជម្រៅអំពីវិធីសាស្រ្តបែងចែក ត្រូវបានលើក ឡើង។

ស្របពេលជាមួយនោះដែរ បញ្ហាផ្សេងៗទៀតនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក៏មានសារៈសំខាន់ណាស់ដែរ នឹងមិនត្រូវបានបំភ្លេចឡើយ។ បន្ថែមលើនេះ ខ្ញុំសូមលើកជូន

កិច្ចប្រជុំដដែកពិភាក្សាជ្រើសរើស ទីកន្លែងសម្រាប់កិច្ចប្រជុំមណ្ឌលតំណាងរបស់យើងបន្ទាប់ និងជ្រើសរើសបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលប្តូរវេណ ដើម្បីជំនួសលោកជំទាវក្នុងអាណត្តបច្ចុប្បន្ន។

មុនបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណក្រុមផ្តល់ប្រឹក្សាដែលទើបបង្កើតថ្មី សហការីអញ្ជើញមកពីអង្គការសុខភាពពិភពលោក ការិយាល័យក្រុមប្រឹក្សាភិបាលនៃមូលនិធិសាកល ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនេះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាមណ្ឌលតំណាងរបស់យើង នឹងទទួលអត្ថប្រយោជន៍ដ៏ធំធេង ពីការចូលរួមចំណែកដ៏មាន តម្លៃក្នុងរយៈពេលប្រជុំ២ថ្ងៃនេះ ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងកោតសសើរ ជូនដល់ DAFT ប្រទេសអូស្ត្រាលីដែលបានផ្តល់ធនធានហិរញ្ញវត្ថុដោយសប្បុរស ដើម្បីចំណាយរៀបចំកិច្ចប្រជុំមណ្ឌលតំណាងលើទី៣នេះ នៅប៉ាពូអាស៊ីណូវែលហ្គីណេ។ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ស្នាក់នៅក្នុងរដ្ឋធានី ព័រម៉ូរេសប៊ី ដោយរីករាយ និង សូមជូនពរអោយកិច្ចប្រជុំមណ្ឌលតំណាង ២ថ្ងៃនេះ ទទួលបាននូវលទ្ធផលល្អប្រសើរ។

សូមអរគុណ !